# សេចក្តីជូនដំណឹងជាសាធារណៈ

ធនាគារ ផេនដា ខមមើសលប៊ែង ម.ក (នីតិវិធីជម្រះបញ្ជី) សូមជម្រាបជូនអតិថិជនរបស់ធនាគារឲ្យបានជ្រាបថា៖

1. យោងតាមនីតិវិធីជម្រះបញ្ជីការិយាល័យអ្នកជម្រះបញ្ជីបានបើកទទួលពាក្យស្នើទាមទារប្រាក់ពីអតិថិជនជាបន្តបន្ទាប់ដើម្បីយកមកពិនិត្យ។

2. ដោយសារចំនួនអតិថិជនដែលបានមកដាក់ពាក្យមានចំនួនច្រើន ការចុះបញ្ជីការលេខ និងការចេញលិខិតបញ្ជាក់ផ្លូវការគឺត្រូវការពេលវេលា ដោយសារក្រុមការងារត្រូវពិនិត្យផ្ទៀងផ្ទាត់ព័ត៌មានទិន្នន័យនិងរៀបចំឯកសារពាក់ព័ន្ធឲ្យបានត្រឹមត្រូវជាមុនសិន ជៀសវាសការយឺតយ៉ាវ និង ខាតពេលវេលារបស់អតិថិជន។

3. ចំពោះការកំណត់អំពីអតិថិជនដែលបានដាក់ពាក្យរួចរាល់ និងត្រឹមត្រូវតាមព័ត៌មានដែលបានផ្ទៀងផ្ទាត់របស់ខ្លួន ធនាគារផេនដា (ការិយាល័យអ្នកជម្រះបញ្ជី) នឹងធ្វើការជូនដំណឹងតាមរយៈបញ្ជីឈ្មោះអតិថិជនដែលបានដាក់ពាក្យរួចរាល់និងត្រឹមត្រូវក្នុងតារាងនៅទីស្នាក់ការនៃធនាគារដើម្បីឲ្យអតិថិជនអាចអញ្ជើញមកពិនិត្យ មុនបិទបញ្ចប់ការដាក់ពាក្យស្នើសុំ។

4. ចំពោះអតិថិជនដែលមិនទាន់បានមកដាក់ពាក្យ ធនាគារនឹងជូនដំណឹងតាមគ្រប់មធ្យោបាយដើម្បីឲ្យមកដាក់ពាក្យ និងបំពេញបែបបទតាមការស្នើសុំដូចគ្នា។

អាស្រ័យហេតុនេះសូមអតិថិជនទាំងអស់រក្សាភាពស្ងប់ស្ងាត់ និងរងចាំចំណាត់ការបន្តទៅតាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះ។

ធនាគារ ផេនដា ខមមើសល ប៊ែង ម.ក (នីតិវិធីជម្រះបញ្ជី)

ព្រះរាជាណាចក្រកម្ពុជា
ផេនដា ខមមើសល ប៊ែង ម.ក
PANDA COMMERCIAL
BANK PLC
KINGDOM OF CAMBODIA